# រឿង

# "វិជ្ជលតិ្តគូលែន"

និពន្ធដោយ លី ធាមតេង

ឆ្នាំ ១៩៦៣

## ចំពូកទីមួយ

សតវត្សទី ២០ ជាសតវត្សមានព្រឹត្តិការណ៍ប្រែប្រួលជាច្រើនអនេក ។

ជួនមនុស្សក៏រករឿងរកហេតុទាស់ទែងគ្នា បង្កើតកោលាហលច្របូកច្របល់ពេញប្រទេស ឬ ពេញពិភពលោក ជួនមនុស្សចេះរួបរួមគិតគូរគ្នា រិះរកមធ្យោបាយដោះស្រាយហេតុភេទកល់យុគនេះ ឱ្យបានធូរស្រាលជ្រះស្រឡះទៅវិញ ។

ប្រទេសកម្ពុជា ដែលកំពុងភប់ប្រទះនឹងសតវត្សនេះដែរ គឺត្រូវចលាចលឧត្បាទនេះកំហែងគម្រាមអស់រយៈកាលយ៉ាងយូរ ។ គ្រឹស្តសករាជ១៩៤៦ គ្រាដែលកងទ័ពជប៉ុននាំគ្នាមកវាតអំណាចលើអាណាចក្រខ្មែរ ហើយទទួលបរាជ័យអស់ទៅវិញ ប្រទេសកម្ពុជាមានភព្វ័សំណាងត្រូវបានទទួលអាណាខេត្តខាងលិចមកជាសម្បត្តិជាតិវិញ ក្រោយដែលត្រូវចែកទៅនៅក្រោមការត្រួតត្រាបរទេស

រយៈពេលជាង៧ឆ្នាំ ។ តែជាអកុសលមួយទៀត ពេលនោះមានពពួកឧទ្ទាមបានលបបង្កបង្កើតចលាចលតាមដោយស្រុកភូមិនិគមទូរទីជាដំបូងគឺនៅអាណាខេត្តប៉ៃកខាងលិច ។

ប្រាសាទបុរាណនានា មានអង្គរវត្តជាដើម ដែលជានិមិត្តរូបនៃដួងព្រលឹងខ្មែរនោះ ឥឡូវក៏ត្រូវឃ្លាតដាច់ស្រយាលពីសន្ដានចិត្តបណ្ដាជនខ្មែរម្ដងទៀត ព្រោះដងផ្លូវដែលសំរាប់ធ្វើដំណើរទៅ កាន់ទីនោះគេប្រព្រឹត្តិទៅដោយពិបាក ត្បិតអសន្តិសុខចាំយាយីជារឿយៗ។

នៅគ្រឹស្តសករាជ ១៩៥៣ ប្រវត្តិសាស្ត្រខ្មែរត្រូវបើកដល់ទំព័រសុវណ្ណដែលមានសំណាងកត់ត្រាយកនូវសម័យខ្មែរបានឯករាជ្យពេញបរិបូណ៌ ។ អសន្តិសុខត្រូវថយឬទ្ធិបន្តិចម្ដងៗ លុះត្រាតែបានស្ងប់ដូចសេចក្ដីប្រាថ្នា នៃជនជាតិខ្មែរទូទៅ ។ អ្នកស្រុកនាំគ្នាធ្វើដំណើរពីភូមិមួយទៅភូមិមួយ ពីខេត្តមួយទៅខេត្តមួយប្រកបដោយកិរិយារីករាយជាទីបំផុត ។ បណ្ដាជនគ្រប់ខេត្តតែងបបួលគ្នីគ្នាត្រសងទៅទស្សនាប្រាសាទអង្គរ ដើម្បីក្រេបជញ្ជាក់យកតំលៃនៃកេរ្តិ៍ស្នាដៃរបស់បុព្វបុរសជាតិខ្លួន ។ ខ្លួនខ្ញុំនឹងមិត្តភក្តិជាច្រើន ក៏បាននាំគ្នាទៅក្រសាលលំហែចិត្ត និង សង្កេតនូវទឹកសិល្បៈរបស់វីរជនខ្មែរ



បូរាណ ជាមួយនិងគេដែរ ។ តែហ្វូងខ្ញុំមិនត្រឹមតែទស្សនាប្រាសាទអង្គរវត្ត ឬប្រាសាទនានានៅតាមវង់ធំ-វង់តូចប៉ុណ្ណោះទេ យើងទាំងអស់គ្នា ត្រូវឆ្ពោះដំណើរទៅកាន់ភ្នំគូលែនទៀត ។ ឮតែឈ្មោះភ្នំនេះ ដួងចិត្តខ្ញុំរន្ធត់បន្តិច ព្រោះពីមុនៗមក ខ្ញុំធ្លាប់ឮថាទីភ្នំនេះជាទីសំរាប់អ្នកស្វែងធម៌ ដើរធ្វើធុតង្គហើយជាទីពេញទៅដោយការភ័យខ្លាចនានា មានសត្វសាហាវ និង ខ្មោចបិសាចអរក្ស បង់បត់ជាដើម ហេតុនេះនៅក្នុងរថយន្តដែលកំពុងលឿនស្ទេវសំដៅភ្នំនេះខ្ញុំតែងមមៃនឹកពុំមានផុតបារម្ភឡើយ ។ រថយន្តលឿនលឿនកាត់ផ្លូវលំដែលមានខ្សាច់ផុសហុយទ្រលោមរត់តាមរថយន្ត ។ ឆ្លងភូមិ, ឆ្លងវាល, ឆ្លងព្រៃព្រឹក្សាលតាវល្លិ៍ រួចទើបទៅដល់ជើងភ្នំ ។

វេលាថ្ងៃត្រង់ជាក់ ពពួកខ្ញុំបានឡើងទៅដល់ខ្នងភ្នំ ហើយបានដើរទៅដល់ទីដែលអ្នកផងធ្លាប់ទៅកំសាន្ត ។ ក្បែរកូនអារាមមួយដ៏ស្ងប់ស្ងាត់ស្រគត់ស្រគំ ដែលពុំមានដំកើងឬកអ្វីសោះព្រោះមានតែកុដិសាលាតូចៗ តម្រៀបគ្នាជាជួរកណ្ដាលធ្លារាបស្មើរយ៉ាងធំទូលាយប៉ុណ្ណោះ មានថ្មមួយដំធំខ្ពស់ ដ៏ជាមហាអាសននៃព្រះពុទ្ធបដិមាទ្រង់ផ្ទុំដ៏ធំសម្បើម ។ អ្នកស្រុកសន្និដ្ឋានដាមទីនេះថា " *កន្លែងព្រះធំ* " គ្រាដែលខ្ញុំរៀបនឹងឡើង ទៅនមស្សការដល់ព្រះពុទ្ធរូបនេះ

ខ្ញុំក្រឡេកទៅឃើញយាយចាស់តាចាស់ពីរនាក់ប្ដីប្រពន្ធកំពុងប្រឹង ជម្រះស្មៅនៅជុំវិញផែនសិលាមហាអាសនៈ ។ ជានិស្ស័យរបស់ខ្ញុំ ដែលនិយមគោរពចាស់ព្រឹទ្ធាចារ្យ, ខ្ញុំក៏ឆ្មៀតចូលទៅលំឱនកាយ គោរពគួរសមនឹងបុគ្គលជរាទាំងពីររូបនោះ ។ គាត់ក៏ម្ចីម្នាងាកមក ថ្លែងស្វាគមន៍ចំពោះខ្ញុំវិញយ៉ាងរោះរាយ :

-ជំរាបសួរលោកតា លោកយាយ ? ( ខ្ញុំពោលព្រមជាមួយ លើកហត្ថសំពះ ) ។

-ថ្វាយព្រះចៅ ! អញ្ជើញមកពីខាងណា ? ( លោកតានោះ ចាប់សួរមកខ្ញុំវិញ )។

-បាទខ្ញុំមកពីកំពង់ចាម !

-ឯណាអីចេះចៅកំពង់ចាម ?

-បាទនៅខាងទន្លេធំលោកតា !

-អូ ! ទន្លេធំហ៎! សុខសប្បាយគ្រាន់ខាងនោះ ?

-បាទស្រួលបួលទេលោកតា ! អត់ទោស! ខ្ញុំសុំលាឡើង ទៅថ្វាយបង្គំព្រះសិន ចាំចុះមកវិញសឹមខ្ញុំមកអង្គុយលេងនឹងតា បន្តិចជាជាងពេលក្ដៅដើរទៅណាមិនស្រួល ។

ពោលរួចខ្ញុំម្ចីម្នាឡើងទៅថ្វាយបង្គំព្រះជាមួយមិត្តភក្តិខ្ញុំ ។



លុះនមស្សការរួចស្រេចខ្ញុំប្រញាប់ចុះមកមុនគេ ដើម្បីសន្ទនាកំសាន្ត ជាមួយតាយាយជម្រះស្មៅនេះទៀត ។ ម្ដងនេះតា និង យាយឈប់ ជម្រះទាំងពីរនាក់ នាំគ្នាមកអង្គុយសន្ទនាលេងជាមួយខ្ញុំហាក់ដូច ធ្លាប់ស្គាល់យូរមកហើយ តែតាមពិតគាត់ពុំដែលស្គាល់សោះ ប៉ុន្តែ ធម្មតានិស្ស័យខ្មែរតែងរោះរាយជាមួយភ្ញៀវអ្នកដំណើរ ជានិច្ចយ៉ាង ហ្នឹង ។

-លោកតានៅលើនេះ មានភូមិគេធំៗ ឬតា ?( ខ្ញុំផ្ដើមសួរទៅ តាម្ដងទៀត ) ។

-ភូមិតូច ៗទេចៅ តែមានច្រើន !

-ភូមិដែលតានៅឈ្មោះភូមិអី !

-តានៅភូមិរូងពស់ !

-តានៅភូមិរូងពស់! ភូមិនេះឆ្ងាយឬតា ?

-ឆ្ងាយណាស់ដែរចៅ

ប៉ុន្តែអ្នកភូមិតាមានទំលាប់នាំគ្នា មកជម្រះស្មៅថ្វាយព្រះនៅ ទីនេះជាញឹកញាប់ណាស់ ។

-យីតា !(យាយនិយាយម្ដង) ត្រង់ហ្នឹងទេដឹង ដែលលោកបង ចាប់និទានរឿងភូងម៉ាឡៃប្រាប់យើងពីល្ងាចមិញ?

-អី ! ត្រង់ហ្នឹងហើយលោកបងចាបគាត់ធ្លាប់ទៅស្គាល់កន្លែងណាទៀត !

-រឿងនាងភូងម៉ាឡៃជារឿងអ្វី តា? (ខ្ញុំសួរប្រញាប់ទៅតាគ្រាដែលឮយាយរំលឹកឈ្មោះរឿងនិទានរបស់តាចាប ព្រោះនិស្ស័យខ្ញុំវាជាអ្នកចូលចិត្តស្តាប់រឿងរ៉ាវណាស់ )។

-រឿងនោះវែងចៅ ប៉ុន្តែអ្នកស្រុកគេនាំគ្នាចងចាំយូរមកហើយ ។

-លោកតាមេត្តានិទានឱ្យខ្ញុំស្តាប់ផងបានទេ!

-តែបើចៅមិនប្រញាប់ទេ សឹមតានិយាយឱ្យស្តាប់

-បាទមិនទាន់ប្រញាប់ទេព្រោះខ្ញុំប្រាថ្នានៅទទួលដំណេកទីនេះមួយយប់ ស្អែកទើបត្រលប់ទៅសៀមរាបវិញ

លោកតាបែរទៅយកកូនសៀនមួយ សិតទឹកពីក្អមពិសារមួយក្អឹក រួចទើបងាកមកចាប់និយាយរឿងប្រាប់ខ្ញុំ

* * *



កាលរាជ្យព្រះបាទយសោវរ្ម័ន ដែនដីខ្មែរយើងល្បីល្បាញខាងឫទ្ធចេស្តាពន់ប្រមាណ ឯបណ្តាអ្នកមានទ្រព្យធនសេដ្ឋី ឬគហបតីក៏មានច្រើនរូបណាស់ដែរ ។ គ្រានោះនៅខេត្តស៊ីសូផុន មានសេដ្ឋីម្នាក់ឈ្មោះ គូរ៉ាតដែលល្បីខ្ចរខ្ចាយថាជាអ្នកមានសម្បត្តិលើសលែង នឹងមានអំណាចគ្រប់គ្រងត្រួតត្រាលើបណ្តាជនលើតំបន់នោះផង ដ្បិតព្រះរាជាសព្វព្រះរាជហឫទ័យនឹងសេដ្ឋីគូរ៉ាតនេះណាស់ បានជាទ្រង់ប្រគលអស់ទាំងអំណាចទាំងឡាយ ត្រួតត្រាប្រជាជនជួសព្រះអង្គហាក់ដូចជាស្តេចក្រាញ់មួយដែរ តែព្រះអង្គមិនទាន់ដំឡើងឱ្យពេញយសនៅឡើយ ។

ពេលព្រលប់ត្រជាក់ ព្រះទិនករជាទីពឹងនៃយើង បានយាងសន្សឹមៗចុះទៅពួកការស្មីជ្រកនៅឯទិសបស្ចឹម បីដូចជាគេចព្រះកាយពីពិភពយើងទៅបំភ្លឺលោកមួយទៀត ។ សេដ្ឋីគូរ៉ាតនៅទំរេតខ្លួនលើគ្រែត្បាញផ្តៅដ៏មានជើងឈើឆ្លាក់ជាក្បាច់យ៉ាងឆើត ។ ដៃគាត់គងថ្ងាស់ ភ្នែកគាត់សំឡឹងលើមេឃដែលពាស់ពេញទៅដោយហ្វូងតារាល្អិតមិរ បញ្ចេញកិរិយាជាអ្នកគិតការមួយរយ មួយម៉ឺនជំពូក ។ តើគាត់កំពុងគិតពីរឿងអ្វីទៅហ្ន៎ គឺគាត់កំពុងមមៃដល់ប្រាក់កាសដែលដាក់ ទុកជាច្រើនសែនដំឡឹងក្នុងឃ្លាំងរបស់គាត់ ។

គាត់នឹកថានឹងរំលែកប្រាក់នោះពាក់កណ្ដាលថ្វាយទៅព្រះមហាក្សត្រិយ៍ ដើម្បីជួយឧបត្ថម្ភដល់ការសាងមន្ទីរពេទ្យ នឹងមន្ទីរសំរាប់ចិញ្ចឹមពួកអ្នកក្រីក្រ ។ មួយសន្ទុះគាត់ងើបក្បាលឡើង ងាកបែរទៅក្រោយយ៉ាងប្រញាប់ ដោយឮស្នូរជើងមនុស្សដើរមក:

-លោកម្ចាស់!( ស្រីម្នាក់ ដើរបង្អោនខ្លួនដៃកាន់កែវទឹកតម្រង់ចូលមក )នេះទឹកក្ដៅដែលលោកបង្គាប់ឱ្យខ្ញុំយកមកជូន

-អើល្អហើយ! ឯងចេញទៅវិញចុះឯងឃើញនាងភូងម៉ាឡៃកូនស្រីអញកំពុងធ្វើអ្វី ?

-ចាំលោកម្ចាស់ អ្នកនាងកំពុងកំសាន្តចិត្តដោយស្ដាប់ពួកស្ត្រីរាំច្រៀងនៅឯក្នុងបន្ទប់ខាងក្នុងនោះ :

-អើទៅចុះ (គាត់ថាដោយលើកដៃជាសញ្ញាផងក្រោយដែលទាសីចេញផុតទៅគាត់បណ្ដែតអារម្មណ៍ជាថ្មីម្ដងទៀត ។ ម្ដងនេះគាត់នឹកដល់វាសនារបស់កូនស្រីសំឡាញ់តែមួយរបស់គាត់ ព្រោះសព្វថ្ងៃនេះសម្បត្តិទ្រព្យសព្វសារពើមានឥតខ្វះ ប្រាថ្នាទុកជាកេរ្តិ៍មត៌កឱ្យបុត្រីបានថ្កុំថ្កើងទៅគ្រាអនាគត ហើយគាត់មិនដែលធ្វើអ្វីឱ្យបុត្រីអាក់ចិត្តឡើយ ទុកណាជានាងចង់បានអ្វីដែលពិបាករកយ៉ាងណា ក៏គាត់ខិតខំស្វែងរកលុះត្រាតែបានបំពេញចំណង់កូនស្រីគាត់។



ពេលដែលលោកសេដ្ឋីកំពុងគិតយ៉ាងនេះ តែបើមានអ្នកណាចូលទៅមើលកូនស្រីគាត់ឯក្នុងបន្ទប់ខាងក្នុងវិញ គេនឹងឃើញនាងកំពុងអង្គុយសើចកក្អៀកជាមួយពួកទាសី ។

មិនយូរប៉ុន្មាននាងក៏បង្គាប់ឱ្យពួកភ្លេង និង ពួកស្រីរាំថយចេញទាំងអស់គ្នាទៅ ដើម្បីយកពេលស្ងាត់ស្ងៀមសម្ងំគេងលើគ្រែឱ្យស្កប់ស្កល់ព្រោះគ្រានេះជាពេលអធ្រាត្រទៅហើយ ។ ចំណែកពួកទាសីជំនិតបីនាក់របស់នាងមិនថយចេញឆ្ងាយឡើយ នាំគ្នាអង្គុយក្បែរជើងគ្រែហើយច្រៀងបំពេមានស្នូរថ្ងំៗ លួងលោមនាងឱ្យគេងលក់ ។

ព្រឹកព្រាងស្វាងអរុណកាលណា ទាសីទាំងបីម្នីម្នាចែកមុខងារគ្នាបំរើនាងជាថ្មីទៀត គឺ នាងម្នាក់សប្បុរសទទួលភារៈជាអ្នកសំអិតសំអាងសក់នឹងលុបលាងមុខមាត់ នាងស្រអែមជាអ្នកកាន់កញ្ចក់ឆ្លុះមុខនឹងកាន់ផ្ចិតបក់ឱ្យនាង ឯនាងខ្មៅជាអ្នកទទួលបំរើផ្សេងៗ ដែលនាងបង្គាប់ឱ្យធ្វើ ។គ្រាណាតុបតែងកាយរួច នាងក្រមុំបុត្រីសេដ្ឋីនាំទាសីជិះរទេះទឹមសេះ បរលែងបន្តិចៗក្នុងសួនច្បារដែលពាស់ពេញដោយបុប្ផាជាច្រើនបែប ចោលគន្ធពិដោរឈ្ងុយឈ្ងប់គួរត្រេកត្រអាល ។ ជូនកាលនាងនាំទាសីទាំងនេះចុះ

លេងទឹកក្នុងស្រះដែលមានដាំឈូក ហើយទឹកថ្លាឆ្វេងលើសលែងកញ្ចក់ ដោយមានស្រ្តីច្រៀងរៀបរាប់ពីព្រឹក្សាលតាវល្លិ៍នឹងបុប្ផានៅក្នុងសួននោះឱ្យនាងស្តាប់ផង ។ គ្រាណាកំសាន្តចិត្តដោយធម្មជាតិទាំងនេះ រួចនាងត្រឡប់ចូលលំនៅវិញហើយទៅក្បែឪពុកសំឡាញ់ នាងឱបក ឱបចង្កេះបញ្ចេញកិរិយាជាធីតាតូច តែស្រឡាញ់ឪពុកណាស់ ។

ឱកាសដ៏ថ្កុំថ្កើងយ៉ាងនេះឥតមានជនណាម្នាក់ស្មានក្នុងចិត្តថាលោកសេដ្ឋីនឹងមានការប្រែប្រួលដូចម្តេចវិញឡើយ ។ តែ.. ជាធម្មតាៈ លោកយើងតែងតែប្រែប្រួលជានិច្ច ។ ពាក្យថា "លោកៈ ប្រែថាវិនាស ស៊ីសេចក្តីថា របស់ក្នុងលោកគឺរបស់កើតហើយវិនាសទៅវិញជានិច្ច " ។

កន្លងពីនេះមួយខែ មានមេកងម្នាក់បានឡើងទៅក្រាបទូលដល់ព្រះរាជាថា " សេដ្ឋីនេះមានចិត្តមិនត្រឹមត្រង់នឹងជាតិទេ ជួនកាលគាត់ឧបត្ថម្ភសំភារៈ ម្ហូបម្ហាផ្សេងៗ ឱ្យពួកខ្មាំងសត្រូវផង " ។ ព្រះអង្គទ្រង់ជ្រាបហេតុការណ៍យ៉ាងនេះ ក៏ទ្រង់ចាត់ឱ្យពួកអាជ្ញាតាមស៊ើបអង្កេតពីកិរិយារបស់សេដ្ឋីនេះឱ្យច្បាស់លាស់ ។ មិនយូរប៉ុន្មាន ព្រះរាជបំរើទាំងនេះ ឡើងក្រាបបង្គំគាល់ព្រះមហាក្សត្រិយ៍



វិញថាពាក្យបណ្តឹងរបស់មេកងនោះពិតទាំងអស់ ។ ព្រះរាជាទ្រង់គង់សញ្ជប់មួយសន្ទុះទើបងើបព្រះកេសឡើងៈ

-នែអ្នករាល់គ្នា ! ពាក្យរបស់អ្នកដែលឡើងមកក្រាបទូលនេះ យើងមិនទាន់ជឿពិតទាំងអស់ទេ ដ្បិតយើងស្គាល់សេដ្ឋីនេះជាយូរមកហើយគួរចំណាំបានថាជាមនុស្សមានចិត្តត្រង់ចំពោះជាតិហើយស្លូតបូតណាស់ហ្នាំ! ។

-ក្រាបទូលព្រះករុណាថ្លៃវិសេស ពីជាន់មុនមកទូលព្រះបង្គំយើងខ្ញុំទាំងឡាយ តែងតែឮពាក្យអ្នកស្រុកសរសើរពីសេដ្ឋីនេះដែរ តែឥឡូវដល់ទូលព្រះបង្គំជាខ្ញុំទៅធ្វើអង្កេតទៅ ស្រាប់តែឃើញថាលោកសេដ្ឋីនេះ មានចិត្តមិនត្រង់នឹងជាតិទៅវិញក្រាបទូល ។

-ចុះអ្នករាល់គ្នាពិនិត្យឃើញការណ៍ដូចម្តេចខ្លះ? បានជាហ៊ានបញ្ជាក់ថាលោកសេដ្ឋីនេះមិនត្រឹមត្រង់?

-សូមទ្រង់ព្រះមេត្តាប្រោស ថ្ងៃដែលទូលព្រះបង្គំទៅដល់ភូមិរបស់គាត់ ស្រាប់តែប្រទះឃើញពួកអ្នកស្រុកដឹកនាំសំភារៈផ្សេងៗទាំងរទេះៗ តម្រង់ទៅព្រៃជាទីប្រទល់ដែន ហើយទូលព្រះបង្គំទាំងឡាយឃាត់រទេះនោះសួរបញ្ជាក់ថាដឹកនាំគ្រឿងសំភារៈទាំងនេះទៅណា? ពួកអ្នកស្រុកឆ្លើយថា "ទ្រព្យទាំងនេះជារបស់

លោកសេដ្ឋីគូរ៉ាត ហើយលោកបង្គាប់ឱ្យខ្ញុំទាំងអស់គ្នាដឹកយកទៅឱ្យពួកចាវព្រាវនៅក្នុងព្រៃធ្វើជាស្បៀងអាហារ

-ចុះអ្នកទាំងអស់នាំគ្នាយកទ្រព្យទាំងនោះទៅណាទៅឥឡូវនេះ ។

-សូមទ្រង់ព្រះមេត្តាប្រោស ! ទូលព្រះបង្គំជាខ្ញុំបានយកមកដម្កល់ទុកក្នុងឃ្លាំងព្រះរាជទ្រព្យហើយក្រាបទូល!

ព្រះនរបតីទ្រង់សណ្ដាប់រួចទ្រង់ងោកព្រះសិរ គឺទ្រង់សញ្ជឹងត្រិះរិះពីហេតុអ្វីមួយធំធាត់ណាស់ ប្រហែលមួយសន្ទុះធំ ទើបទ្រង់អនុញ្ញាតឱ្យគេធ្វើចុតហ្មាយបណ្ដេញសេដ្ឋីចិត្តក្បត់នេះ ចេញពីទីប្រជុំជន ហើយត្រូវរឹបអូសយកសម្បត្តិទ្រព្យដែលសេសសល់ទាំងប៉ុន្មាន មកធ្វើជាសម្បត្តិផ្ទាល់របស់រាជការ ។

វេលានេះហើយដែលមហាសេដ្ឋី នឹង បុត្រីសំឡាញ់របស់គាត់ដែលធ្លាប់តែរុងរឿង បានធ្លាក់ខ្លួនជាជនសាមញ្ញហើយទាបថោកលើសលែងគេឯង ដោយមានព្រះរាជតម្រាស់ឱ្យហូតងារយសសក្តិប្រគល់ទៅមេកងដែលចូលមកទូលប្ដឹងដល់ព្រះអង្គនោះទាំងអស់ ។ សេដ្ឋីគូរ៉ាតរលីងទ្រព្យពីខ្លួន ត្រូវចាកចេញពីលំនៅអាត្មាតែគាត់ទាល់ប្រាជ្ញាពន់ពេក ដ្បិតមិនដឹងទៅនៅស្រុកណាសោះ



ហើយមិនដឹងជាប្រកបការអ្វីផង ព្រោះតាំងពីតូចមក គាត់មិនដែលទៅរៀនធ្វើរបរជំនាងអ្វីមួយប្រចាំជីវិតសោះ សូម្បីតែការភ្ជួររាស់ធម្មតា ក៏គាត់មិនចេះ ។ រំពឹងលើកូនស្រីក៏រឹតតែណាស់ទៅទៀត គ្រាន់តែដណ្ដាំបាយឱ្យគាត់បរិភោគក៏បានដោយពិបាក ។ គាត់សែនចំបែងពេក នាំតែកូនដើរពីភូមិមួយទៅភូមិមួយ រហូតដល់ទៅជើងភ្នំគូលែន ដែលមានតែកូនភូមិតូចតាចជ្រកនៅក្រោមដើមឈើធំៗប៉ុណ្ណោះ ។

-ក្មួយអើយ! ក្មួយឯងទៅណាមកណាបានជាមកដល់ភូមិខ្ញុំនេះ? តាចាស់ម្នាក់សួរទៅអតីតសេដ្ឋីគូរ៉ាត គ្រាដែលឃើញគាត់ឈររារែកជាមួយនិងកូនស្រី ។

-បាទលោកមា! ខ្ញុំនេះមនុស្សសាត់ព្រាត់ និរាសពីស្រុកកំណើតមករកទីអាស្រ័យនៅទីនេះ ជាមួយលោកមាផង សូមលោកមាជួយទំនុកបំរុងខ្ញុំផង:

-មិនអីទេក្មួយ ! អ្នកស្រុកមានេះសុទ្ធតែមនុស្សចិត្តធម៌ល្អណាស់ តែភូមិនេះមិនសូវមានម្ហូបអាហារអ្វីឆ្ងាញ់ពិសារទេ ។

-ខ្ញុំឥតគិតពីម្ហូបទេលោកមា បើលោកមាបានអ្វីពិសាខ្ញុំសុំទទួលទានឱ្យដូចនោះទៅបានហើយ ។

-អើបើក្មួយព្រមព្រៀងយ៉ាងនេះ មាអាចទទួលក្មួយឱ្យនៅជាមួយបាន ចុះនាងស្រីឯនោះត្រូវជាម៉េចនឹងក្មួយឯង?

-ជំរាបប្រសាសន៍លោកមា នេះជាកូនស្រីរបស់ខ្ញុំតែមួយ គាត់និយាយដោយចង្អុលកូនស្រីផង ឥឡូវនេះខ្ញុំសុំលោកមាជ្រកនៅទាំងពីរនាក់នេះ តែខ្ញុំនៅមិនទាន់ដឹងច្បាស់ថា តើនៅស្រុក ភូមិនេះគេបានអ្វីធ្វើរបររកទទួលទាន ?

-ក្មួយអើយ ភូមិនេះអ្នកស្រុកគេតែងតែនាំគ្នាដើរបរបាញ់សត្វយកសាច់វាបរិភោគ ហើយនឹងយកស្បែក នឹងស្នែងវាទៅដូរយករបស់ប្រើប្រាស់ដូចជាសំពត់អាវជាដើម ។

-ចុះក្រៅពីបរបាញ់សត្វ មានរបរអ្វីទៀតទេ លោកមាដ្បិតខ្ញុំមិនចេះបាញ់សោះ

-ក្រៅពីបរបាញ់ មានតែត្បាញកន្ទេល, កញ្ជើប៉ុណ្ណោះ ។

-ចំណេះទាំងនេះក៏ខ្ញុំមិនចេះទៀត ព្រោះមួយជាតិខ្ញុំហើយខ្ញុំឥតបានរៀនវិជ្ជាទាំងនេះប្រចាំជីវិតទេ ។

-ហ៊ឺ !(តាដកដង្ហើមធំ) ក្មួយអើយ បើនេះក៏ក្មួយឯងមិនចេះ នោះក៏ក្មួយឯងមិនចេះ តើឱ្យមារកការរបរអ្វីឱ្យក្មួយឯងធ្វើបាន ។ មិនត្រូវដូច្នេះទេក្មួយ! មនុស្សយើងមួយជាតិត្រូវរៀនឱ្យចេះវិជ្ជាអ្វី



មួយសំរាប់ប្រចាំជីវិតណាំក្មួយ ដ្បិតវាសនាយើងមិនទៀង មិនប្រាកដទេ ជួនទៅមានទ្រព្យបរិបូរណ៍ ជួនក៏ចុះក្រដុនដាប យើងត្រូវស៊ីពោះលោះកំឡាំងនឹងរបរទាំងនោះណាំក្មួយ ប៉ុន្តែឥឡូវមានឹកឃើញរបរមួយបែបងាយបន្តិច

-របរអ្វីលោកមា ?

-ឱ្យក្មួយឯងនឹងកូនស្រីនេះ ឧស្សាហ៍ឡើងទៅលើចង្កេះភ្នំឬលើខ្នងភ្នំដើររកបេះផ្លែគូលែន ហើយយកមកផ្ទះយើង លុះព្រឹកឡើងត្រូវក្មួយឯងនឹងចៅស្រីរែកតាមមា មាននាំយកទៅលក់ឯក្រុងអង្គរធំណាំក្មួយ...

ឮពាក្យនេះភ្លាម សេដ្ឋីគូរ៉ាតរឹតតែដាក់មុខជ្រុបទៅទៀត ដ្បិតមួយជីវិតគាត់ហើយ មិនដែលទៅរែកអីបានមួយកូនកន្ត្រាំង ឬ មួយកញ្ជើរទេ ណាមួយគាត់មិនចង់ឱ្យទៅជួបមុខ នឹងរាជធានីអង្គរធំផង ព្រោះខ្លាចជួបនាហ្មឺនសព្វមុខមន្ត្រី ដែលស្គាល់គាត់ពីគ្រាមុន ។ គិតផង គាត់សំឡឹងទៅក្រោយផ្ទះតាផង ក៏ប្រទះឃើញកូនរទេះសាលីមួយតូច និងគោញីមួយនឹម ទើបនិយាយឡើងទៀត

-គិតតាមខ្ញុំចុះលោកមា !

-គិតថាម៉ែចហ្នំ វាគ្មានផ្លូវអីផ្សេងពីនេះទេ

-គិតថាបើខ្ញុំនាំយកបានផ្លែគូលែនមកដល់ផ្ទះ ហើយសូមលោកមាយករទេះសាលីនេះ ទឹមមេគោមួយគូនោះដឹកយកទៅលក់ទៅបានហើយ ?

-អូឱ្យមាយកមេគោមកទឹម? តាមធម្មតាគេមិនដែលយកគោញីទឹមទេ ណ្ហើយមិនអីទេ បើក្អួយថាច្នោះក៏មាយល់តាមដែរ។ ចាប់តាំងពីថ្ងៃនោះមក អតីតសេដ្ឋីនិងកូនស្រីគាត់ បានប្រែក្លាយទៅជាអ្នកបេះផ្លែគូលែន ។ រាល់ព្រឹកតាចាស់នោះតែងដាក់ផ្លែគូលែនមកលក់ឯទីក្រុងជានិច្ច ហើយអ្នកស្រុកផងគេចូលចិត្តនាំគ្នាចាំទិញគាត់ប្រញាយ ព្រោះកាលនោះមិនសូវអ្នកណាចេះបេះផ្លែឈើលក់ទេ ទោះសម្បូណ៌ក៏ដោយ ។

គេនាំគ្នាចំណាំមុខតានោះ ដោយគេដាក់ឈ្មោះគាត់ថា "តាគោមេ " ព្រោះគាត់តែងទឹមគោញីរាល់ ៗ ព្រឹក ។

មិនយូរប៉ុន្មានរបរលក់ផ្លែគូលែននេះ ផ្តល់ដើមទុនដល់តានិង អតីតសេដ្ឋីច្រើនគួរសម នាំឱ្យគាត់បែកប្រាជ្ញាផ្សេងៗ ទៀតៈ

-កូនសំឡាញ់ឪពុក(សេដ្ឋីគូរ៉ាតហៅនាងភួងម៉ាឡៃ)ធម្មតាមនុស្សនីមួយៗ តែងស្វែងរកសុភមង្គលរៀងៗខ្លួន ចំណែកយើងក៏ត្រូវស្វែងរកដូចអ្នកផងដែរ ជាការធំបំផុតត្រូវឪពុកស្វែងរកសុភមង្គលឱ្យកូន ដើម្បីកុំឱ្យកូនលំបាកវេទនារហេមរហាមទៅគ្រាមុខ តែកូនអើយ! និយាយដល់ត្រង់នេះសេដ្ឋីអួលដើមក តសំដីឱ្យលះភ្លាមទៅមិនបាន... សព្វថ្ងៃយើងធ្លាក់ខ្លួនទូរន់ទូរាយ៉ាងនេះ... តើឱ្យឪពុករកសុភមង្គលឯណាបាន ជាតិនេះជាជាតិអភ័ព្វរបស់យើងណាកូន ។



-ណ្ហើយលោកឪពុក! សូមលោកកុំបារម្ភអ្វីចំពោះសុភមង្គលសំរាប់កូននោះ ចូរលោកពុកគិតយ៉ាងណាឱ្យតែបានសុខកាយ សប្បាយចិត្តលោកពុកទៅបានហើយ

-បើឱ្យឪពុកសុខកាយបន្តិចនោះ ឪពុកទើបនឹកឃើញរបរមួយផ្សេងទៀតឃើញថាងាយ ហើយមិនសូវប្រើកំលាំងដូចនេះពេក ។

-របរអ្វីលោកពុក មានប្រសាសន៍ឱ្យកូនដឹងផង ក្រែងកូនអាចជួយគិតអារកាត់បាន

-ហ៊ុ ... (ឪពុកដកដង្ហើមធំងាកមុខចេញបន្តិចទើបបែរមកវិញ) របរនេះ កាលដើមឡើយយើងមិនដែលនឹកនាដល់ម្តងទេ តែគ្រានេះកូនអើយ កាលសម័យត្រូវបង្គាប់ឱ្យឪពុករកទិញមេគោហើយ

ឡើងទៅចិញ្ចឹមលើខ្នងភ្នំ ដើម្បីយកកូនវាលក់យកប្រាក់លៀងជីវិត។

នាងកញ្ញាឱនក្បាលមិនចេញស្តី មួយសន្ទុះទើបងើបឡើង ពោលដោយផ្ទៃមុខញញឹមទៅកាន់ឪពុក ។

-យោបល់លោកពុកប្រសើរហើយ ដ្បិតជាការធូរកំលាំងបន្តិច តែយើងត្រូវនាំយករឿងនេះទៅពិគ្រោះនឹងតាផង ។

-មែនហើយកូន, មើលទៅតាក៏គាត់មិនយល់ទាស់ដែរ

-លោកពុក! បើយើងទៅនៅលើខ្នងភ្នំ មុខជារលីកតាល្មោចហើយ ។

-មិនអីទេ បើរលឹកសឹមមកលេងនឹងគាត់ម្តងៗ ព្រោះមិនជាឆ្ងាយប៉ុន្មានទេ បើយើងធ្លាប់ឡើងចុះរាល់ថ្ងៃទៅ

-លោកពុក នៅលើខ្នងភ្នំយើងបានអីនៅ ? រងាណាស់ឬទេលោកពុក :

-យើងត្រូវធ្វើខ្ទមមួយសំរាប់ជ្រកនៅ ឯរងាឬមិនរងានោះវាមិនជាស្អីទេ ដ្បិតយើងធ្លាប់នៅស្រណុកស្រួលយូរមកហើយ ។ កូនស្រី! ការក្រនឹងមាន ការពិបាកនឹងស្រណុក ជាគូគ្នាហ្នាំកូន បើយើងធ្លាប់សប្បាយរីករាយរួចមកហើយ យើងត្រូវតែខំទ្រាំលំបាកវេទនាម្តងទៅ ។ ដូច្នេះឪពុកសូមផ្តាំកូនថា បើថ្ងៃមុខ ថ្ងៃក្រោយកូន



បានឡើងជាអ្នកមានថ្កុំថ្កើង គួរកូនឆ្លៀតពេលមមៃដល់ទុក្ខវេទនារបស់អ្នកក្រខ្សត់ម្តងៗ ផងកូនមិនបាច់មើលឆ្ងាយទេ គ្រាន់តែសង្កេតពួកបាវព្រាវបំរើនោះទៅបានហើយ ។

កំពុងតែនិយាយគ្នា តាម្ចាស់ផ្ទះក៏ដើរចូលមក នាំឱ្យជនទាំងពីរនាក់ឪពុក.កូននិយាយពិគ្រោះអំពីគំនិតរបស់ខ្លួនភ្លាមទៅ ។ ក្រោយដែលបានស្តាប់សព្វគ្រប់ តាក៏ឥតហ៊ានឃាត់ខាំងអ្វីឡើយព្រោះគាត់យល់ថា មនុស្សពិបាកចិត្តបែបនេះ គួរតែបណ្តោយតាមចំណង់ទៅចុះ ។

* * *

សូមរង់ចាំអានជាបន្តនូវរឿងៈ
" **ទឹកទន្លេសាប** " របស់អ្នកនិពន្ធ **គឹម ហាក់** ដែលជាប្រលោមលោកបែបមនោសញ្ចេតនា នាទសវត្សឆ្នាំ ១៩៣៩ ។ ដែលនឹងចេញផ្សាយពីបណ្ណាគារដដែលក្នុងពេលឆាប់ៗខាងមុខនេះ !!!

## ចំពូកទីពីរ

ចាប់តាំងពីថ្ងៃនោះមកជនទុរគ៌តពីរនាក់ឪពុក-កូន បានលាចាកលំនៅតានេះ ទៅសង់ខ្ទមតូចមួយនៅក្នុងភូមិ"រូងពស់" លើខ្នងភ្នំគូលែន ។ សុភមង្គលរបស់ជនទាំងពីរ គ្មានអ្វីជាជាងដើរគៀងហ្វូងគោតម្រង់ទៅវាលស្មៅ ដើម្បីបំប៉នចំណីអាហារសត្វ ឯខ្លួនគេវិញ អង្គុយបីតបារីស្លឹកសង្កែ បង្គុយផ្សែងក្រោមដើមឈើ ។ ចំណែកភូងម៉ាឡៃនាងត្រូវនៅចាំខ្ទម ជូនកាលនាងទៅឃ្វាលគោជំនួសឪពុកនាងម្តងៗ គ្រាណាឪពុកនាងមិនស្រួលខ្លួន ។ វេលាមួយដែលជាឱកាសបុណ្យចូលឆ្នាំ ពួកអ្នកភូមិផងរបងជាមួយ គេកេណ្ឌគ្នាទាំងហ្វូងទៅជម្រះស្មៅនៅទីដែលដំកល់ព្រះ ពុទ្ធបដិមាករទ្រង់ធំ



មួយអង្គស្ថិតនៅលើផែនថ្មយ៉ាងខ្ពស់ ដែលគេនាំគ្នាសន្មត់ហៅថា "កន្លែងព្រះធំ " ។ នាងភូងម៉ាឡៃ មានប្រថ្នាចង់ទៅរកធ្វើបុណ្យនេះនឹងគេណាស់ :

-លោកពុក ( នាងចូលទៅជិតឪពុក គ្រាដែលឪពុកកំពុងដេកសំរាកកំឡាំង ) កូនចង់សុំលោកពុកទៅជម្រះស្មៅថ្វាយព្រះឯកន្លែងព្រះធំនឹងគេដែរព្រឹកស្អែកនេះ ។

-ទៅបាននរណារៀបម្ហូបទុកឱ្យឪពុក ដល់ឪពុកត្រឡប់មកពីឃ្វាលគោវិញ ។

-មិនអីទេលោកពុក ពួកគេទៅនោះក៏មិនទៅពីព្រលឹមពេកដែរ ចាំព្រឹកឡើង កូនដណ្តាំបាយ និងរៀបចំទុកជូនលោកពុករួចទើបកូនទៅ :

-អើកូនទៅក៏ទៅចុះ ទៅធ្វើបុណ្យធ្វើទាននឹងគេទៅកុំឱ្យជាតិក្រោយអភ័ព្វតោកយ៉ាកដូច្នេះទៀត !

-ចាំះកូនក៏ចង់ប្រាថ្នាដូចនេះដែរ! លោកពុកសូមលោកពុកក្រោកឡើង អញ្ជើញទៅពិសារបាយ កូនរៀបជូនហើយស្រេច!

-មក! កូនឯងក៏មកអាស្រ័យជាមួយគ្នាឱ្យហើយទៅ

ព្រោះថ្ងៃជិតលិចទៅហើយ ។ យប់នេះចន្លុះយើងវានៅសល់តិចណាស់ ដ្បិតពីថ្ងៃនេះឪពុកមិនបានរកជ័រមកធ្វើថែមទៀតទេ ។

អ្នកទុរគតិពីរនាក់ឪពុកកូន ក៏ចូលបរិភោគអាហារជាមួយគ្នាដោយមានទឹកមុខស្ងួតស្ងប់ពន់ប្រមាណ ។ លុះបរិភោគរួចនាងភួងម៉ាឡៃ ត្រូវរំលែកបាយដែលសល់ខ្លះ ឱ្យទៅឆ្កែមួយគូរបស់នាង ដែលសំរាប់ជួយរត់គៀងហ្វូងគោ ហើយដែលជាទីស្រឡាញ់របស់អ្នកទាំងពីរណាស់ ដ្បិតឆ្កែនេះចេះនាំផ្លូវយ៉ាងស្ទាត់ជំនាញក្នុងវេលាណាដែលម្ចាស់វាវង្វេងផ្លូវ ។

រាត្រីស្ងប់ស្ងាត់ នៅលើខ្នងភ្នំគ្មានអ្វីក្រៅពីសូរសត្វព្រៃយំម្តងៗ នឹងយូរៗ គេឮសូរខ្យល់បក់បោកមែកឈើធំៗនោះ ឱ្យឮប្រាវហាក់ដូចជាមានមហន្តរាយអ្វីមួយ ។ ឯសន្សើមក៏រោយរុះផង់ល្អិតមីរ ត្រជាក់សែនត្រជាក់លើសពីសន្សើមនៅភូមិនានា ដែលជាទីទំនាបធម្មតា ។

ក្រោយដែលបញ្ចូលហ្វូងគោទៅក្នុងក្រោល ហើយវាយរនុកជាប់ស្រួលបួលរួច នាយគង្វាលកំសត់ក៏ចូលនិទ្រាប្របកូនស្រីសំឡាញ់ តែគាត់មិនទាន់លង់លក់ភ្លាមទេ ហាក់ដូចជាការត្រិះរិះរបស់គាត់នោះមានមួយសែនជំពូក ដែលគាត់រកអាវកាត់មិន



ដាច់ស្រេចសោះ ។

-ភួងម៉ាឡៃ! គេងមិនទាន់លក់ទេឬកូនស្រីឪពុក!
(នាយគង្វាលហៅកូនគ្រាដែលឃើញកូនប្រែប្រួលខ្លួន )

-ចាំមិនលក់ទេលោកពុក !

-កូនឯងនឹកអ្វីបានជាគេងមិនលក់ នឹកដល់រឿងព្រឹកស្អែកត្រូវទៅឯព្រះធំឬ!

-មែនហើយលោកពុក! កូនឮថានៅពេលចូលឆ្នាំនេះមានពួកអ្នកក្រុងអង្គធំនាំគ្នាមកលេងដែរ

-ចុះបើគ្រាន់តែគេមកដែរ វាមានទៅទាស់អី! យើងសប្បាយតែពួកយើងទៅជម្រះស្មៅថ្វាយព្រះតើ ពួកគេក៏ស្រេចតែគេទៅ !

-លោកពុក! បើកាលណាកូនឃើញពួកអ្នកក្រុងដែលគេរៀបចំខ្លួនប្រាណស្អាតបាតហើយ កូននឹកខ្មោចចិត្តជាមិនខាន ព្រោះនឹកទៅដល់គ្រាដែលយើងមានទ្រព្យធនបរិបូរណ៍ មានខ្ញុំកំដរប្រើប្រាស់គ្រប់គ្រាន់ ។

-ហ៊ឺ !( នាយគង្វាលដកដង្ហើមធំ) កូនអើយកុំនឹកដល់រឿងនោះពេក ចូរកូននឹកកាត់ចិត្តថាការក្រនេះ ជនណាក៏តែងចង់

វៀរចាកដែរ ប៉ុន្តែកូនអើយ ! នេះវាជាព្រេងវាសនាដែលព្រះព្រហ្មលោកសាងឱ្យយើងទេតើ ដូច្នេះយើងត្រូវតែញញឹមទទួលព្រេងវាសនាយើងហ្នាំកូនទុកជាតោកយ៉ាកយ៉ាងណាក៏យើងកុំថ្ងូរ ត្រូវតែប្រឹងតស៊ូឱ្យផុត!

-ចុះព្រះព្រហ្មលោកម៉េចក៏ចូលចិត្តធ្វើឱ្យក្រលំបាកម្ល៉េះ ម៉េចក៏មិនធ្វើឱ្យតែសម្បូណ៌ សប្បាយដូចយើងកាលគ្រាមុនទៅលោកពុក!

-កូនអើយ ( នាយគង្វាលក្រោកអង្គុយ ) ឱ្យលោកសាងសុទ្ធតែសម្បូណ៌សប្បាយឯណាបាន បើព្រេងសំណាងយើងពីអតីត ហើយចិត្តយើងក្នុងបច្ចុប្បន្នមិនសូវចេះកាន់ធម៌អា សូមមេត្តាដល់អ្នកទីទាល់សោះចូរកូនដឹងថា ថ្ងៃនេះនៅទីក្រុងម្ល៉េះ សមមានពួកអ្នកសម្បូណ៌លុយកាក់ដើរលេងសប្បាយតាមដោយរោងមហាស្រព ឬ តាមរមណីដ្ឋានមិនចេះខ្វះ គេសប្បាយរាំច្រៀងស៊ីផឹកតាមចំណង់ឥតមាននឹកនាដល់ជនពួកខ្លះទៀតដេកនៅក្នុងខ្ទមកន្ទ្រប់បង្ហូរទឹកភ្នែកជាមួយគ្រួសារដោយការក្រលំបាកសោះទេ

-ចុះម៉េចក៏ពួកអ្នកមានទាំងនោះ គេមិនចេះនឹកដល់អ្នកក្រខ្សត់សោះលោកពុក !



-កូនមាសឪពុក ! យើងក៏ដឹងស្រាប់ដែរកាលដែលយើងនៅមានទ្រព្យសម្បត្តិ យើងគិតតែសប្បាយនឹងវត្ថុប្រើប្រាស់មិនចេះខ្វះ និងខ្ញុំកំដរឆ្វេងស្តាំឥតមើលដៃអ្នកទីទាល់ដែលសំពះអង្វរសុំសេចក្តីសប្បុរស, យុត្តិធម៌ពីយើងទេ, ណ្ហើយកូនកុំនិយាយរឿងនេះទៀត យើងបានជាខុសហើយបំភ្លេចវាឱ្យសូន្យទៅ។

ឮឪពុកហាមឃាត់ដូច្នេះ នាងភ្លូងម៉ាឡៃដកដង្ហើមធំរួចខំសម្ងំកំព្រនស្តាប់សូរសម្រែកខ្លែងស្រាក់ នឹងកូកយំទទួលរំលែកទុក្ខពីនាង ។ ក្រៅពីសម្រែកសត្វស្លាបទាំងនេះ មានសូរប្រើសក្តាន់ប៉ុបរកគ្នាទាំងហ្វូងៗ ។ឯជនទុរគ៌តពីរនាក់ឪពុកកូនខំធ្មេចភ្នែកលុះត្រាលង់លក់ស៊ប់ទៅ ។

ព្រឹកព្រាងស្វាងកាលណា ព្រះទិនករឧទ័យត្រដែតត្រសែតខ្ពស់ផុតចុងព្រឹក្សា នាងភ្លូងម៉ាឡៃរៀបចំម្ហូបចំណីទុកជូនឪពុករួចទើបលីចបមួយទៅជាមួយហ្វូងនារីទាំងឡាយ ។

មិនយូរប៉ុន្មានក៏បានទៅដល់កន្លែងព្រះធំ ។ គ្រានោះនាងក្រឡេកពីចំងាយទៅ ឃើញព្រះពុទ្ធបដិមាករមួយអង្គយ៉ាងធំសំបើមទ្រង់ផ្ទំនៅលើផែនថ្មមួយជុំទៀត មានកំពស់ផុតចុងឈើដល់ត្រង់

នេះពួកនារីខ្នងភ្នំនាំគ្នាលុតជង្គង់នមស្សការ ដល់ព្រះពុទ្ធរូបដែលនៅខ្ពស់ហាក់ជាប់ពពកនេះពីក្រោមទៅ ។

ឯនាងភួងម៉ាឡៃក៏សំពះវន្ទាដូចគេដែរ នាងតែងបន់ស្រន់ប្រាថ្នាសុំឱ្យខ្លួននាងនឹងឪពុកនាង បានជួបប្រទះនឹងភ័ព្វវាសនាល្អឡើងវិញ ។ គោរពរួចស្រេច គេនាំគ្នាកាន់ចបរៀងខ្លួន តាំងជំរះស្មៅដែលដុះជុំវិញផែនថ្មជាទីតម្កល់ព្រះពុទ្ធរូបនេះ ប្រណាំងប្រជែងគ្នាដូចជាឥតហត់សោះ :

-វើយ ! ថ្ងៃណាស់ហើយ (សម្លេងនារីម្នាក់ស្រែកឡើង) យើងល្មមនាំគ្នាទៅងូតទឹកម្តង ហើយត្រឡប់មករកបាយទឹកឱ្យរួចសិនសឹមជម្រះទៀត ។

-អី! ល្មមឈប់សិនហើយ (នាងម្នាក់ទៀតតប)

-ចុះយើងបានទឹកឯណាងូតបង ? ( នាងភួងម៉ាឡៃសួរទៅនាងម្នាក់ដែលចាស់ជាងគេ )

-មិនខ្វះទេទឹកនោះ ប្អូនឯងមិនទាន់ដឹងទេ គេទៅងូតឯកន្លែងទឹកធ្លាក់ហ្នាំ

-ចុះឯណាទៅកន្លែងទឹកធ្លាក់ ?

-មិនឆ្ងាយទេប្អូន!មកយើងនាំគ្នាទៅ ។ ថាហើយពួកនារី



ទាំងនេះនាំគ្នាដំរង់ទៅកន្លែងទឹកធ្លាក់ ដែលនៅពីខាងជើងទីនេះបន្តិច ។ នៅក្នុងព្រៃលើខ្នងភ្នំនេះ មានប្រាសាទថ្មមួយស្កុកស្កមណាស់ដែរ តែពួកនារីយើងមិនគិតរវល់ចូលពិនិត្យប្រាង្គសិលានេះទេ ដ្បិតគេប្រញាប់ឱ្យដល់កន្លែងងូតទឹក ។ មិនទាន់ដល់ផងគេឮតែសូរទឹកហូរទម្លាក់ខ្លួនពីលើប្រឡាយទឹកជ្រោះធ្លាក់ទៅលើផែនថ្មយ៉ាងធំ លាតខ្លួនស្អាតរលងបីដូចទីវាលបូកដោយបាយ អបពេញសព្ទឈូឆរ ៗ ឥតស្រាក់នាំឱ្យអ្នកផងស្មានថាផែនទឹកពោកខ្លួនខ្លាំងៗ ទៅលើផ្ទាំងថ្មយ៉ាងនេះមុខជារិចរិលថ្មអស់ហើយ ។តែមិនអីសោះថ្មនៅតែស្អាតដដែលគួរជាទីកំសាន្តរបស់អ្នកដំណើរ ដែលឡើងទៅងូតទឹកថ្លាឆ្វង់បីដូចកញ្ចក់នេះលេង ។

-មកវើយផ្លាស់ឱ្យឆាប់ៗ ទឹកថ្លាល្អណាស់ ។ ផ្លាស់សំ-លៀកបំពាក់រួចហ្វូងនារីយើងតាំងនាំគ្នាចុះតម្រង់ទៅលើផ្ទាំងថ្មដូចកំរាល ដែលមានទឹកហូររឹម ៗ តាមចន្លោះថ្មរកេតរកូត ។

-បង ! បងមានដឹងទេ (នាងភួងម៉ាឡៃសួរទៅនារីចំណាស់) តើដើមទឹកនេះហូរចេញពីណាមក ?

-បងមិនដឹងសោះ ព្រោះបងសួរចាស់ៗគាត់ក៏មិនដឹង

ច្បាស់ដែរ គាត់គ្រាន់តែចង្អុលប្រាប់ថាមកពីហ្នុំ ! ដោយពិតមិនដឹងមកពីណា តែទឹកនោះនៅតែហូរខ្ទប្រាំងវស្សាដូច្នោះឯង !

-មកនរណាបេះផ្កាបណ្តែតប្រណាំងគ្នាវើយ (នារីម្នាក់នាំអាទិ៍ ) របស់នរណាលឿនជាង ?

-មិនបាច់បណ្តែតផ្កាទេ បណ្តែតខ្លួនយើងតាមទឹកវិញសប្បាយជាង !

-ទេកុំលេងបណ្តែត យើងនៅក្រោមរងទឹកដែលធ្លាក់វិញឱ្យស្រួលសរសៃ! មើលហ្នុំ! បែកពពុះស្គុល ។

លុះលោតកញ្ឆ្រោកបោកបាចប្រលែងប្រលូកគ្នាក្នុងទឹកសប្បាយរួចហើយ នារីទាំងនេះនាំគ្នាឡើងផ្លាស់សំលៀកបំពាក់រួចទៅរកទីតម្រេតងត្រង់ប្រាសាទថ្មរៀង១ខ្លួន ។ ចំណែកនាងភួងម៉ាឡៃ នាងមិនទាន់ព្រមឡើងទេ នាងនៅគៀចង្ងូតតែម្នាក់ឯងទៀតបណ្តោយឱ្យគេឡើងទៅមុនចុះ នាងថាចាំទៅក្រោយគេក៏បាន ។ វេលាដែលគេទៅផុតអស់បុត្រីរបស់នាយគង្វាល អង្គុយលេងលើថ្មតែម្នាក់ឯង ជូននាងក្រាបបណ្តែតខ្លួនតាមកម្លាំងទឹកហូររឹម១ ជូននាងអង្គុយជុសក្អែល ឬ សម្ងឹងសព្ទព្រឹក្សាលតាវល្លិ៍ដែលដុះធ្លាក់ធ្វិនប្រទាក់គ្នា ហើយដែលមានម្លប់ត្រឈៃមកគ្របលើនាង ។ គយគន់



សព្ទគ្រប់នាងច្រៀងលេងកែកំសាន្ត ដោយរាប់រៀបពីទេសភាពត្រង់នេះ ។

សម្លេងបក្សាបក្សីស្រែកឆ្លើយឆ្លងគ្នាមានសូរប្លែក១ដូចយ៉ាងប៉ុលតោកនឹងសរសេះភ្នំជាដើម ។ ឯទោចលោតប្រដេញគ្នាតាមស្ទួរមែកឈើស្រែកបញ្ចេញសំលេងក្រលូច គួរឱ្យអ្នកដែលមិនធ្លាប់ ឮព្រឺខ្លាចប៉ុន្តែនាងក្រមុំភួងម៉ាឡៃ នាងធ្លាប់ជួបប្រទះនឹងសំឡេងនេះជានិច្ចមកហើយ ក៏ឥតមាននឹកក្រែងបារម្ភអ្វីឡើយប្រែជាដូចគ្រឿងបំពេរ ឬ កំដរនាងទេវិញ ។ គួរឆ្ងល់ណាស់ហ្នុំ! ផ្ទាំងថ្មនេះត្រូវរងកម្លាំងផែនទឹកធ្លាក់មកលើដូច្នេះ ម៉េចក៏មិនរិចរិលសោះហ្នុំ!" នាងតែងនឹកយ៉ាងនេះ ជារឿយ១ដោយភ្នែកសម្លឹងគយគន់នាយអាយសព្ទទាំងព្រឹកព្រៃនៅក្បែរខ្លួននាង ។ មិនយូរប៉ុន្មាន ផ្កាមួយទងអណ្តែតមកប៉ះខ្លួននាងពីក្រោយខ្នង នាងក៏ចាប់រើសឡើងពិនិត្យ មើលថាតើផ្កានេះអណ្តែតពីណាមក ឬ មួយទើបតែជ្រុះមកថ្មី១ តែការសង្កេតនេះមិនដាច់ស្រាច់សោះ ។ នាងនឹកថា: ប្រសិនជាផ្កានេះជ្រុះហើយអណ្តែតពីឆ្ងាយមក ម៉េចក៏មានទងនៅជាប់វែងជាប់ទាំងស្លឹកផង ? ឯស្នាមទងដូចជាទើបតែកាច់ថ្មី១នាំឱ្យនាងនឹកឃើញថា : "ច្បាស់ជាមានមនុស្សណានៅលើទឹក

កាច់ទងផ្កានេះទម្លាក់បណ្ដែតមកជាប្រាកដ " ។ នឹកដូចនេះនាងក៏ក្រោកឈរឡើង ងើបក្បាលមើលទៅខាងលើជាទីដើមទឹកដែលធ្លាក់មក ។

នាងគ្មានទទួលសូរអ្វីក្រៅពីសូរទឹកទម្លាក់ខ្លួនឮឈូឆរ។ នោះទេ ឯទិដ្ឋភាពវិញ ក៏នាងគ្មានយល់អ្វីក្រៅពីចុងរុក្ខជាតិយោលចុះ យោលឡើងតាមកម្លាំងខ្សែព្រះពាយទាញទៅមក។ ដូចជាឥតបេះថ្ងូរថាហត់នឿយសោះដែរ ។

"ឱហ្ន៎! ផ្កាលើខ្នងភ្នំក៏មានសម្រស់ដូចផ្កានៅក្នុងសួនឯទីក្រុងដែរ ! យើនារីនៅក្នុងសមសាន្ត ក៏មានរូបឆោមមិនចាញ់បុត្រីរបស់អ្នកធំនៅរាជធានីឡើយ! . . .

សូរសម្លេងបុរស់ម្នាក់ឮហ៊ឹម។ ពីក្នុងគុម្ពឈើមួយជ្រុំនាំឱ្យធីតានាយគង្វាលនឹកឆ្ងល់ ក៏ឈរស្រឡាំងកាំងរកមើលរូបម្ចាស់សំលេងពុំយល់ ។ បន្តិចមកសូររងំ។ នេះឮឡើងទៀត :

.." ម្ដេចក៏ផ្កាមិនទៅដុះនៅកណ្ដាលទីក្រុងឱ្យសមនឹងលំអទៅ ! ម្ដេចក៏មកសម្ងំរូបឆោមពណ្ណរាយ នៅកណ្ដាលទ្រូងព្រៃភ្នំក្រំថ្មដូច្នេះ វាសនាផ្កាអ្វីក៏ថោកថយអ្វីម្លេះ ។ ឱផ្កាអើយ ! កាលណាឡើយបានខ្ញុំទៅស្រង់យកផ្កាឱ្យទៅនៅរុងរឿងឯទីក្រុងវិញបាន? រំដួល



នៅភ្នំគូលែនមានក្លិនក្រអូបមែនហ្ន៎!

ឮសម្លេងនេះម្ដងទៀត នាងភួងម៉ាខ្សៃក្រោកឡើងពីក្នុងទឹកទៅឈរលើថ្មមួយដុំ រំពៃគយគន់ឱ្យយល់ច្បាស់ពីសូរនិមិត្តនេះ។

គ្រានោះនាងបានប្រទះភ្នែកនឹងរូបប្រុសម្នាក់លេចធ្លោឡើងចំត្រង់កន្លែងដែលឮសូរអម្បាញ់មុិញនេះ ។ នាងភ័យរន្ធត់ស្ទុះរត់ឲ្យម្រង់ទៅរកហ្វូងនារីឯទៀត ជាមិត្តភក្ដិតែមិនបានរ៉ាយរឿងដែលបានជួបប្រទះនេះប្រាប់ដល់ពួកនារីទាំងនោះទេ ។ នាងខំបបួលនារីទាំងនេះឱ្យត្រលប់ទៅភូមិស្ថានខ្លួនវិញ ។ ជួនជាពេលនោះព្រះទិនករក៏ស្រុតចុះបន្តិចទៅឯផង ហ្វូងបុត្រីអ្នកភូមិរូងពស់នាំគ្នាលីចបមួយម្នាក់ដើរយ៉ាងលឿន ដោយឥតបង្អែបង្អង់ឡើយ :

-យើងគួរស្រូតឱ្យលឿនបន្តិចបង !(ភួងម៉ាខ្សៃពោលទៅកាន់នារីចាស់ជាងគេ ) ដ្បិតខ្ញុំបន្ទាន់ទៅដណ្ដាំបាយជូនលោកពុកខ្ញុំផង ហើយបងរាល់គ្នាក៏ជិតដល់ពេលរៀបចំម្ហូមម្ហាដែរ ។

-អើ! យើងគួរតែស្រូតហើយពេលនេះកុំឱ្យល្ងាចទាន់នាំឱ្យឪពុកម្ដាយយើងបារម្ភ ។

នារីទាំងអស់ចេះតែនាំគ្នាដើរលឿនស្លុងទៅ ឯនាងភួងម៉ាខ្សៃវិញនាងមិនអស់ចិត្តសោះ ចេះតែដីរផងងាកក្រោយផង

ដ្បិតនាងឮសូរដីពីចំងាយដូចជាស្នូរជើងសេះផាយ ។ លុះដល់ត្រង់វាលមួយរាងទូលាយបន្តិច ហើយខាងក្រោយនោះត្រង់ភ្លឺង នាងក៏ប្រទះឃើញចំនុចខ្មៅមួយបោលលឿនស្ទុងកាន់តែជិតមកៗ នាំឱ្យនាងរឹតតែបារម្ភឡើង ខ្លាចក្រែងមានមហន្តរាយអ្វីដល់រូបនាង ឬរូបឪពុកនាង:

_បង!បងមើលក្រោយ (នាងហៅគេឱ្យជួយមើល)អីនុ៎ះដូចមនុស្សជិះសេះ ?

_អឺ! មនុស្សជិះសេះមែនហ្នាំ ( នារីទាំងអស់ឆ្លើយព្រមគ្នាឡើង )

_យើងគិតរត់ឬបង? ដ្បិតផ្ទះយើងក៏ជិតណាស់ហើយមើលឃើញដំបូលផ្ទះហើយ

_រត់ក៏រត់ទៅ កុំឱ្យមនុស្សនោះមកទាន់ ! ហ្វូងនារីនាំគ្នារត់អស់ទំហឹង ឥតរវល់គិតថានៅតាមផ្លូវលំនោះមានបន្លា ឬ កូនឈើអ្វីឡើយ ។ ដោយការខំប្រឹងពេក មិនយូរប៉ុន្មានក៏បានទៅដល់ផ្ទះរៀងខ្លួន ។ នាងភូងម៉ាឡៃរត់ចូលទៅក្នុងលំនៅ ចាប់កញ្ឆក់ ផ្អាំងបាយមកប្រកបការនាង ឯនាយគង្វាលជាឪពុកកំពុងអង្គុយបីតបារីស្លឹកសង្កែមួយយ៉ាងធំ បង្អុយផ្សែងទ្រលោមប៉ើង



រសាត់ទៅលើភ្នែកគាត់ រំពៃមើលផ្តែគង្វាលគាត់មួយគូ ដែលជាអ្នកជួយប្រមូលហ្វូងគោគាត់ ដែលកំពុងប្រលែងគ្នាពីមុខផ្ទះ ។

ស្នូរជើងសេះមកដល់ភ្លាម នាយគង្វាលងើបក្បាលបែរទៅមើល យល់រូបបុរសម្នាក់អាយុប្រហែលជា២៥ឆ្នាំ បែបជាកូនអ្នកក្រុង តែស្លៀកពាក់ជាអ្នកដើរព្រៃ ។ គេលោតចុះពីខ្នងសេះយ៉ាងប្រញាប់ ហើយលែងខ្សែបង្ហៀសេះចោល ស្ទុះចូលមកក្នុងផ្ទះ ដោះមួកបង្អោនក្បាលគោរពនាយគង្វាលតាមការគួរសម នាយគង្វាលនៅស្រឡាំងកាំង រៀបតែនឹងហាមាត់សួរ ស្រាប់តែបុរសអ្នកដំណើរនិយាយឡើង :

_អត់ទោសលោកមា! ឱ្យខ្ញុំសុំទឹកទទួលទានបន្តិច !

កាលឮដូច្នោះភ្លាម បុរសចំណាស់កាន់តែបើកភ្នែកធំ ៗ ហើយដើរទៅជិត !

_ចុះអ្នកធ្វើដំណើរពីណាមក បានមកសុំទឹកខ្ញុំនៅទីនេះ

_បាទលោកមា ខ្ញុំនេះវង្វេងផ្លូវមួយថ្ងៃវាល់ល្ងាចហើយ

_តើអ្នកធ្វើដំណើរទៅឯណា បានជាវង្វេងផ្លូវ ឬ មិនធ្លាប់ដើរព្រៃភ្នំទេ !

_សូមលោកមាអាណិតដាក់ទានទឹកឱ្យខ្ញុំបន្តិចសិន ទើបខ្ញុំ

មានកំលាំងនឹងរាប់រៀបជំរាប !

ឮដូច្នោះនាយគង្វាលស្រែកហៅធីតាគាត់ :

-ភួងម៉ាឡៃ ដងទឹកមួយផ្តិលមក

កាលឮឈ្មោះនេះភ្លាម អ្នកដំណើរបើកភ្នែកធំ ៗ សញ្ជឹងតែម្នាក់ឯងថា "ឈ្មោះល្អណាស់ពិរោះផង ម៉េចក៏អ្នកនៅកណ្តាលទ្រូងព្រៃភ្នំចេះរកឈ្មោះឱ្យកូនអីល្អម្ល៉េះ ឬ មួយជាជាន់ដើមធ្លាប់មានរាជធានីនៅទីនេះដែរ"។ ការងឿងឆ្ងល់នេះមិនទាន់ដាច់ស្រេចក្នុងចិត្តផង ស្រាប់តែបុរសវង្វេងផ្លូវឃើញនារីរូបឆើតម្នាក់ ដែលហាក់ដូចជាខ្លួនស្គាល់ពីមុននោះ ចេញមកដកាន់ទាំងទឹកមួយផ្តិលមកផង ។ តាឪពុកចង្អុលទៅភ្ញៀវ នាងក៏ហុចផ្តិលទឹកទៅតាមបង្គាប់ឪពុក

-អរគុណនាង! (អ្នកវង្វេងផ្លូវទទួលអំណរគ្រាដែលបានទទួលទឹកពីនារី )

រួចហើយនាងក្រមុំដើរចូលទៅប្រកបការ ឯក្នុងផ្ទះបាយវិញ ចំណែកភ្ញៀវកម្លោះយើង ចេះតែខំរំពៃភ្លេចទាំងគិតក្រែងដល់កែវភ្នែករបស់តាឪពុក ដែលកំពុងសំឡក់ថ្ងៃដូចភ្នែកឆ្មាគ្រាប្រទះកណ្តុរ :



-ជំរាបប្រសាសន៍លោកមា! ខ្ញុំជាកូនជនសាមញ្ញម្នាក់នៅក្បែររាជធានីអង្គរធំ ហើយថ្ងៃនេះអផ្សុកពេក ក៏ជិះសេះរកបរបាញ់សត្វជាការកំសាន្តសប្បាយ ។ ក្នុងពេលដែលខ្ញុំដេញតាមឈ្លូសស្មាវមួយដែលរត់លឿនស្ទុងកាត់ព្រៃ នាំល្បឿនសេះខ្ញុំឱ្យលឿនតាមផង ។ ខ្ញុំគិតតែពិនិត្យដានឈ្លូសឥតរវល់ចំណាំផ្លូវទេ គ្រាតែឡើងមកដល់លើខ្នងភ្នំ ស្រាប់តែឈ្លូសនោះបាត់ដានមិនដឹងទៅទីណា ។ ដូច្នេះខ្ញុំក៏នៅឡេឡាកណ្តាលព្រៃរាវរកផ្លូវឱ្យប្រាកដនឹងធ្វើដំណើរចុះទៅវិញមិនឃើញសោះ :

-ចុះហេតុម្តេចក៏អ្នកឯងបានមកដល់ភូមិខ្ញុំនេះ ឬមួយជាឈ្លូសនោះនាំអ្នកមកដល់ភូមិនេះ ?

-បាទលោកមា! កាលខ្ញុំបាត់ដានឈ្លូសមិនមែនបាត់នៅភូមិនេះទេ គឺនៅឆ្ងាយពីនេះ ប៉ុន្តែកាលខ្ញុំក្តួលចិត្តរកផ្លូវមិនឃើញនោះខ្ញុំចុះពីខ្នងសេះ ដឹកបណ្តើរក្នុងព្រៃមិនដឹងទិសតំបន់ ស្រាប់តែទៅដល់កន្លែងទឹកជ្រោះហូរធ្លាក់ឮសូរឆរៗ ក៏ប្រទះនឹងនារីមួយហ្វូង កំពុងងូតទឹកប្រលែងប្រល្វូកគ្នា សើចហ៊ោកញ្ជៀវ ខ្ញុំក៏ខំជិះសេះតាមនារីទាំងនោះរហូតមកដល់លំនៅលោកមានេះ។

ចុះនាងដែលយកទឹកមកមុននេះតើត្រូវជាម៉េចនឹង

លោកមា ?

-នាងជាកូនស្រីរបស់ខ្ញុំតែមួយ ដែលនៅកំសត់កម្រនឹងភូមិនេះជាមួយខ្ញុំ ។

លោកមា សូមលោកមាមេត្តាជួយគិតយ៉ាងណាជួយជូនខ្ញុំទៅរកឃើញផ្លូវត្រឡប់ទៅវិញផង ។

-មិនអីទេឱ្យតែឆ្កែខ្ញុំទាំងពីរវាជូនទៅជាការស្រេចព្រោះក្នុងព្រៃនេះវាថ្មឹកជាងខ្ញុំទៅទៀត

ថារួចនាយគង្វាល ទះដៃជាសញ្ញាហៅឆ្កែមកដល់ភ្លាម

-នែអាពាល, អាធក់, ឯងនាំក្មួយនេះទៅដល់ផ្លូវចុះទៅត្រង់ភូមិពាមហ្នាំ !

នាយព្រានកំឡោះបង្អោនខ្លួនលាតាគង្វាល នឹងងាកទៅងក់ក្បាលលានាងក្រមុំដែលកំពុងតែយកទឹកក្តៅមកជូនឪពុក ។ រួច ស្រេចក៏បំផាយសេះតាមឆ្កែមួយគូដែលរត់លឿនស្លុងពីមុខមិនយូរ ប៉ុន្មានឡើយ ឆ្កែរបានទៅដល់ផ្លូវចុះមួយយ៉ាងទូលាយធ្វើឱ្យអ្នកវង្វេងសប្បាយចិត្តក្រៃលែង ។ វេលានោះឆ្កែនាំផ្លូវក៏បោលត្រឡប់លំនៅវាវិញ ឯបុរសកំឡោះរឹតតែបំផាយសេះលឿនស្ទេវទៅទៀតផ្សិត ពេលកាន់តែល្ងាចទោទន់ណាស់ទៅហើយ ។ សាយណ្ហ



សម័យថ្ងៃ ស្រុតទាបហៀបលិចដែលពាក្យចាស់ហៅថា" ថ្ងៃគងភ្នំ" បុរសបាន មកដល់លំនៅយ៉ាងស្កុកស្កម្ភនៅក្នុងរាជធានី ដែលវេលានោះពួកបាវព្រាវទាំងហ្វូង កំពុងឈររង់ចាំដំណើរ ។ ចៅកំឡោះលោតចុះពីខ្នងសេះភ្លាមពួកបាវរត់មកទទួលបង្ហៀសេះពីដៃម្ចាស់ដោយមានអាការៈយ៉ាងគោរព ។

-លោក! អ្នកស្រីម្តាយលោកទន្ទឹងលោក តាំងពីថ្ងៃត្រង់ម្ល៉េះ (ទាសីម្នាក់រត់មកជិតហើយពោល) តើលោកអញ្ជើញទៅដល់ព្រៃណាខ្លះបានជាយូរម្ល៉េះ ?

-ឱ! ខាន់អើយ! គ្នាវង្វេងផ្លូវទៅរហូតដល់ភ្នំគូលែនឯនោះ!

-យ៉ាងហ្នឹង បានជាខ្ញុំនាំគ្នាទន្ទឹងមិនដាច់ផ្អែកទេ សូម្បីតែទៅទទួលទានបាយក៏មិនហ៊ានទៅផងនៅអត់តែទាំងអស់គ្នានេះ

-ណ្ហើយឥឡូវទៅរកបាយទឹក កុំបារម្ភទៀតខ្ញុំមកដល់ហើយ ។

ចៅកំឡោះនិយាយសើចផង រួចក៏ឡើងទៅលើលំនៅដែលនៅពេលនោះមានសភាពអ៊ូអរលើសមុនបន្តិច ។

វត្សា! វត្សា គឺជានាមរបស់ចៅកំឡោះដែលបានប្រែក្លាយខ្លួនស្លៀកពាក់អាវព្រៃ ដើបរបាញ់វង្វេងផ្លូវនេះ ។

វត្សាជាកូនប្រុសតែមួយរបស់សេដ្ឋី "សុម្បា" ដែលជាអ្នកកំពូលសម្បត្តិនៅក្នុងរាជធានី ។ ពិតមែនតែជាបុត្ររបស់គំនរប្រាក់តែវត្សាឥតបានទទួលការចេះដឹងអ្វីឱ្យពិតប្រាកដទេ ព្រោះគេរវល់តែដើរសប្បាយចង់ធ្វើអ្វីតាមចិត្ត សូម្បីតាំងពីការប្រមាញ់រហូតទៅ ។

ចាប់តាំងពីបានប្រទះភ្នែកនាងនឹងក្រមុំនៅលើខ្នងភ្នំមក វត្សាតែងនឹកស្រមៃឃើញរូបនាងនៅថ្មីៗ ,ឃើញកាលនាងអង្គុយត្រាំនៅក្នុងទឹក, យកដៃវែកទឹក, ច្រៀងសំម្លេងស្រួយស្រេះ នឹកកាលនាងរើសផ្ការបស់ខ្លួនបណ្តែតទៅនោះពិនិត្យ ។ នឹករហូតទៅដល់លំនៅតូចរបស់នាង ហើយនាងយកទឹកមកហុចឱ្យខ្លួន គ្រាដល់ខ្លួនគោរពលានាងមកទៀត ។

"ឱហ្ន៎ ផងបព្វតាមានក្លិនបុប្ផាក្រអូបមែន ពិតនាំឱ្យខ្ញុំខ្លោចប្រមាត់រលួយថ្លើមដោយអាល័យក្លិនផ្កាព្រៃភ្នំនេះ ព្រះឥន្ទព្រហ្មយមយក្សណាដែលនាំឱ្យទៅប្រទះនឹងភាពរាងទន់ភ្លន់ល្អឥតល្ខៃរបស់នាងនេះ ឬ មួយជាលោកយល់វាសនាពីអតីតរបស់ខ្ញុំថា នាងនេះត្រូវជា



គូនឹងខ្ញុំពីជាតិមុនមក? យី! ភ្លូងម៉ាឡៃ, ភ្លូងម៉ាឡៃ, ឈ្មោះនេះល្អលើសឈ្មោះអ្នកក្រុងធំទៅទៀតមិនសមបើកប់កាយបាត់នៅឯតំបន់ស្ងាត់ជ្រងំដូច្នេះសោះ "។

រឿងដដែលនេះវត្សាបានគិតជាច្រើនលើកច្រើនគ្រាឥតភ្លេចសោះ ទើបដើរចូលទៅជិតម្តាយក្នុងគ្រាដែលម្តាយកំពុងសំរាន្តននៀលលេងលើក្តាងឿក្រឡាញ់វលងស្រិល ។

-អ្នកជាយ ! បើតាមកូនស្មានថា នៅក្នុងពិភពលោកនេះឥតមាននរណាមានចិត្តធម៌នឹងចិត្តមេត្តាល្អលើសអ្នកជាយទេ!

ឮកូនវាចាដូច្នេះ ភរិយាសេដ្ឋីនៅស្ងៀមជញ្ជឹងមួយសន្ទុះទើបញញឹមទៅកូនវិញ

-អ្នកជាយគឺជាទេពអប្សរពិត ៗ (វត្សាបន្តសំដី) ដែលចេះប្រមើលមើល នឹងចេះជួយសង្គ្រោះមនុស្សលោក

-វត្សា! ឯងនិយាយនេះម្តាយដឹងហើយ (ភរិយាសេដ្ឋីតបទៅកូនដោយសើចផង) ម្តាយដឹងថា ឯងមុខជាមានរឿងអ្វីមួយយ៉ាងចំឡែក ដែលត្រូវនិយាយក្នុងវេលានេះមែនទេ ?

-ពិតណាស់ អ្នកជាយពិតជាចេះឆ្លុះមើលចិត្តកូនមែន

-អើឯងត្រូវនិយាយអីនឹងម្តាយ និយាយមកម្តាយចាំស្តាប់

មើល៍

-អ្នកដាយអើយ! នេះមិនអ្វីក្រៅពីវាសនារបស់កូនពីជាតិមុនមកទេបានជាកាលដែលកូន ទៅបាញ់សត្វវង្វេងផ្លូវនោះទៅរហូតដល់លើខ្នងភ្នំគូលែន...អ្នកដាយ!...ត្រង់ទីនោះស្ទាត់មែនតែជាសុភមង្គលរបស់កូនទេវិញ... ព្រៃព្រឹក្សាទាំងអស់ចេះ ញញឹមហើយហាក់ដូចជាអង្វរឱ្យកូននាំគេយកមកនៅ ឯទីក្រុងផងអ្នកដាយ !

-វត្សា! ម្ដាយពិបាកស្ដាប់ណាស់ពាក្យកូនឯងវាវាងទៅផ្លូវឆ្ងាយពេកហើយជ្រៅជ្រះពេក ចូរកូនបំព្រួញឱ្យងាយស្ដាប់មើលមើល៍

-អ្នកដាយ ! កូនស្មានតែព្រៃភ្នំនោះសុទ្ធតែព្រៃមិនដឹងថាព្រៃភ្នំមានកម្រងផ្កាល្អស្រស់ មិនចាញ់ផ្កានៅទីក្រុងយើង ដូច្នេះសោះ ហើយក្លិនផ្កានោះប្រហែលជាក្រអូបសុទ្ធសាធប្រសើរផងអ្នកដាយ :

-ចុះផ្កានៅព្រៃ វាមានផ្កាអីក៏កូនថាល្អម្ល៉េះ? បើខ្លាំងណាស់ត្រឹមតែរំដួល, ព្រហ្មផាន់ ឬ ក្រវ៉ាន់ប៉ុណ្ណោះ ទៅស៊ីអីរូបរាងនឹងក្លិនកូឡាប, នារជី, ន្ទូនស្រី, ក្ដាំងងារ, ចម្ប៉ា, ណាគ្រី,



ចន្ទធូ ឬពុទ្ធឆាត (ពុទ្ធជាតិ) ដែលដុះក្នុងសួនមុខផ្ទះយើងនេះ ។ កូនមើលចុះ ដុះប្រទាក់ប្រទងគ្នាឥតខ្ចោះ ម្ដេចក៏កូនទៅសរសើរឯផ្កាភ្នំទេវិញ !

វត្សា អង្អែលចុងជើងម្ដាយហើយថា :

រឿងនេះ បើតាមពិតកូនត្រូវតែសុំអនុញ្ញាតពីអ្នកដាយជាមុនរួច រួចសឹមនិយាយជំរាបតាមត្រង់ !

ភរិយាសេដ្ឋីសើចចំអកហាក់ដូចជាយល់ន័យរបស់កូនហើយទើបតឿនកូន :

-វត្សា! ឯងចង់និយាយពីរឿងអីនិយាយភ្លាមៗមក ចូរដឹងថាម្ដាយមានការសន្ទឹកណាស់ណាំ មិនមែនទុកពេលស្ដាប់រឿងវាងវៃរបស់កូនឯងទេ

-អ្នកដាយ! គឺជាភព្វរបស់កូនពិតៗ បានជានាំកូនវង្វេងផ្លូវឱ្យទៅរហូតដល់ភូមិរូងពស់ទៅលើខ្នងភ្នំ ទីនោះមានតែកូនខ្មុតូចៗទេ ប៉ុន្តែមាននារីម្នាក់ជាបុត្រីអ្នកគង្វាលគោ មានរូបឆោមល្អណាស់អ្នកដាយ !

-ហ្ន៎! មែនៗថា ! ម្ដាយថាកិរិយាឯងដែលមមេះមមោះនឹងម្ដាយនេះ គ្មានអីចង់និយាយពីរឿងស្ត្រីទេ

-បើអ្នកដាយជ្រាបច្នេះហើយ គួរតែអ្នកដាយមេត្តាជួយឱ្យបានសំរេចបំណងផងអ្នកដាយ

-ម្តាយមិនដឹងថាម៉េចទេ បើឯងទៅត្រូវចិត្តអីស្រីនៅដោយភ្នំយ៉ាងនេះ ប្រហែលលោកពុកឯងគេមិនយល់តាមទេមើលទៅ

-បើលោកពុកមិនយល់ព្រមតាមទេ សូមអ្នកដាយនិយាយជាមួយលោកពុកផង ដ្បិតកូនស្រលាញ់នាងនោះខ្លាំងណាស់ កូនបានសច្ចាក្នុងចិត្តជាស្រេចថាមិនបាននាងនោះមកធ្វើគូទេ កូននឹងលាលោកពុក អ្នកដាយទៅបួសនៅលើកំពូលភ្នំរហូតមួយជាតិហើយអ្នកដាយ :

-វត្សា! ម្តាយចំឡែកដែរចិត្តកូនឯង ខ្វះអ្វីនារីក្រមុំអ្នកមានមុខមានមាត់មានសម្បត្តិទ្រព្យនៅក្នុងទីក្រុង ម៉េចក៏កូនមិនចាប់ចិត្ត?

-នេះពិតជានិស្ស័យកូនពីអតីតហើយអ្នកដាយ បានជានាំចិត្តកូនរត់ឆ្លងវាល ឆ្លងព្រៃរហូតទៅដល់កំពូលភ្នំយ៉ាងនេះ ។

-ណ្ហើយ! ម្តាយក៏មិនហ៊ានសំរេចដែរ តែចាំម្តាយនិយាយនឹងឪពុកកូនសិន



កាលឮម្តាយទទួលភារៈយ៉ាងនេះ វត្សាក៏លាម្តាយក្រោកចេញដើរតម្រង់ទៅក្នុងបន្ទប់ផ្ទាល់ខ្លួន ហើយប្រះប្រាណននៀលមិនសុខតែម្នាក់ឯង ។ ប៉ុន្តែដោយការនឿយណាយពីពេលថ្ងៃខ្លាំងពេក ក៏ខំបិទភ្នែកឱ្យជិតត្រាតែលង់លក់ទៅ ។

* * *